**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៥១២.០២១.០៩២ ព្រក.សហក.ធាន

*ថ្ងៃអង្គារ ១៣កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤*
*រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១*

# សេចក្តីប្រកាសព័ត៌មាន
## ការចុះអនុស្សរណៈយោគយល់ ស្តីពីការផ្លាស់ប្តូរព័ត៌មានពាក់ព័ន្ធការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរវាង អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និង រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

នៅថ្ងៃអង្គារ ១៣កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ៣:០០ រសៀល នៅធនាគារជាតិនៃកម្ពុជា អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានចុះអនុស្សរណៈយោគយល់ ស្តីពីការផ្លាស់ប្តូរព័តិមានពាក់ព័ន្ធការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធ ដែលមកពីស្ថាប័នទាំងពីរ។

ការចុះហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីពីការផ្លាស់ប្តូរព័តិមានពាក់ព័ន្ធការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនេះ គឺជាសក្ខីភាពមួយដ៏មានសារៈសំខាន់ក្នុងការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការក្នុងស្រុកជាមួយអាជ្ញាធរពាក់ព័ន្ធ ដែលជាកិច្ចខិតខំប្រឹងប្រែងរួមក្នុងការស្វែងរក ទប់ស្កាត់ និងបង្ក្រាប រាល់សកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដើម្បីធានាសន្តិសុខ ជំនឿទុកចិត្ត និងសុវត្ថិភាពជូនប្រជាពលរដ្ឋ និងចូលរួមចំណែកជាមួយសហគមន៍អន្តរជាតិ ក្នុងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ផងដែរ។

អនុស្សរណៈយោគយល់នេះ គឺជាអនុស្សរណៈយោគយល់លើកទី ១៧ រវាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងស្ថាប័នមានសមត្ថកិច្ចក្នុងស្រុក។

ស.ហ.ក

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧